# ប្រកាសដំណឹងល្អរបស់យើង

នៅពេលអ្នកធ្វើសកម្មភាពនេះ សូមរកមើលការបង្រៀនពីព្រះយេស៊ូវគ្រីស្ទ ដែលអាចជួយអ្នកក្នុងការខិតខំរបស់អ្នកដើម្បីចែកចាយអំណរនៃដំណឹងល្អរបស់ទ្រង់ ។

សូមអានវគ្គបទគម្ពីរ ហើយបំពេញការណែនាំនៅក្នុងប្រអប់បួនជ្រុងនីមួយៗ ។ ប្រសិនបើអ្នកត្រូវការកន្លែងច្រើនទៀត អ្នកអាចប្រើផ្នែកបញ្ច្រាសនៃសំណៅចែកនោះ ។

គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៩:២

*សូមសរសេរខគម្ពីរនេះឡើងវិញតាមពាក្យសម្ដីរបស់អ្នក ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៩:៣

*គូរតំណាងនៃខគម្ពីរនេះ ។ ( កណ្ដាប់ស្រូវគឺជាបាច់នៃគ្រាប់ធញ្ញជាតិ ហើយជានិមិត្តរូបនៃមនុស្សដែលទទួលយកដំណឹងល្អ ) ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៧៩:៤

*សរសេរអ្វីដែលអ្នកជឿថាជាពាក្យ ឬឃ្លាដ៏សំខាន់បំផុតនៅក្នុងខគម្ពីរនេះ និងការពន្យល់ខ្លីៗអំពីមូលហេតុដែលអ្នកមានអារម្មណ៍ថា វាសំខាន់ក្នុងការចែកចាយដំណឹងល្អ ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨០:១

*សូមស្វែងរកវគ្គចំណេះចំណានខាងគោលលទ្ធិ ឬបទគម្ពីរផ្សេងទៀតដែលទាក់ទងនឹងខគម្ពីរនេះ ។ សូមសរសេរសេចក្ដីយោងនៅក្នុងប្រអប់បួនជ្រុងនេះ ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨០:២

*សូមសរសេរហេតុផលមួយដែលអ្នកគិតថាព្រះអម្ចាស់ប្រទានដៃគូពួកអ្នកផ្សព្វផ្សាយសាសនា ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨០:៣

*សូមសរសេរពីរបៀបដែលអ្នកមានអារម្មណ៍ថា ខគម្ពីរនេះអាចទាក់ទងនឹងការខិតខំរបស់យើងផ្ទាល់ ដើម្បីចែកចាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨០:៤

*សូមសរសេរអ្វីមួយដែលអ្នកបានឮ ជឿ ឬដឹងថាជាការពិតអំពីព្រះយេស៊ូវគ្រីស្ទ ឬដំណឹងល្អរបស់ទ្រង់ ។ សូមបញ្ចូលមូលហេតុដែលសេចក្ដីពិតនោះអាចមានតម្លៃសម្រាប់អ្នកដទៃដើម្បីស្ដាប់ ។*

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨០:៥

*សូមអានខគម្ពីរនេះ ហាក់ដូចជាកំពុងនិយាយដោយផ្ទាល់ទៅកាន់អ្នក ។ សូមសរសេរពីរបៀបដែលការដឹងថា ព្រះអង្គសង្គ្រោះបានត្រាស់ហៅអ្នកឲ្យចែកចាយដំណឹងល្អ អាចផ្ដល់ឲ្យអ្នកនូវទំនុកចិត្តដើម្បីធ្វើដូច្នេះ ។*

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៤ by Intellectual Reserve, Inc. All rights reserved. PD80007812_258_282-1